ព្រះរាជាណាចក្រកម្ពុជា

ក្រសួងការបរទេស

ជាតិ សាសនា ព្រះមហាក្សត្រ

និងសហប្រតិបត្តិការអន្តរជាតិ

## ខ្លឹមសារជំនួបរវាងឯកឧត្តម អ៊ុច បូរិទ្ធ
## រដ្ឋមន្ត្រីស្តីទីនៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និង
## ឯកឧត្តម Ivo Barek អនុប្រធានព្រឹទ្ធសភានៃសាធារណរដ្ឋឆែក

* * * * * * * * *

ឯកឧត្តម អ៊ុច បូរិទ្ធ រដ្ឋមន្ត្រីស្តីទីនៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បាន អនុញ្ញាតិអោយ ឯកឧត្តម Ivo Barek អនុប្រធានព្រឹទ្ធសភានៃសាធារណរដ្ឋឆែក និងសមាជិកគណៈប្រតិភូ ដែលរួមមានឯកឧត្តមអនុប្រធានគណៈកម្មាធិការទទួលបន្ទុកសុខាភិបាល និងនយោបាយសង្គម នៃព្រឹទ្ធសភា និងសមាជិកព្រឹទ្ធសភានៃសាធារណរដ្ឋឆែកជាច្រើនរូបទៀត ចូលជួបសម្តែងការគួរសម នៅព្រឹកថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៧ វេលាម៉ោង១១ និង៣០នាទី នៅទីស្តីការក្រសួង។

ឯកឧត្តមរដ្ឋមន្ត្រីស្តីទី អ៊ុច បូរិទ្ធ បានសម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅចំពោះឯកឧត្តម Ivo Barek អនុប្រធានព្រឹទ្ធសភានៃសាធារណរដ្ឋឆែក និងសមាជិកគណៈប្រតិភូ ដែលបានអញ្ជើញមកបំពេញទស្សនកិច្ចនៅកម្ពុជា និងបានគូសបញ្ជាក់អំពីទំនាក់ទំនងដ៏ជិតស្និទដែលមានតាំងពីយូលង់ណាស់មក ហើយដែល **ព្រះករុណា ព្រះបរមរតនកោដ្ឋ** បានកសាង និងបន្សល់ទុកមក ព្រមទាំងទំនាក់ទំនងពិសេសដែល**ព្រះករុណា ព្រះបាទ សម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** មានជាមួយនិងសាធារណរដ្ឋឆែក។ ឯកឧត្តម អ៊ុច បូរិទ្ធ ក៏បានវាយតម្លៃខ្ពស់ចំពោះកិច្ចសហប្រតិបត្តិការទ្វេភាគីដ៏ល្អប្រសើរនៃប្រទេសទាំងពីរ កម្ពុជា-ឆែក ដែលកន្លងមកនេះមានការផ្លាស់ប្តូរទស្សនកិច្ចមន្ត្រីថ្នាក់ខ្ពស់រវាងប្រទេសទាំងពីរ និងបានកត់សំគាល់ដោយពេញចិត្តអំពីកំណើននៃវិស័យពាណិជ្ជកម្មនៃប្រទេសទាំងពីរ ដែលមានការកើនឡើងជារៀងរាល់ឆ្នាំ។ តាងនាមរាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា ឯកឧត្តម អ៊ុច បូរិទ្ធ ក៏បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះរដ្ឋាភិបាល និងប្រជាជននៃសាធារណរដ្ឋឆែក ដែលបានផ្តល់ជំនួយអភិវឌ្ឍន៍ដល់ប្រទេសកម្ពុជា ចាប់តាំងពីការរំដោះចេញពីរបបខ្មែរក្រហម រហូតមកដល់បច្ចុប្បន្ន។ ជាពិសេស សាធារណរដ្ឋឆែកបានបង្វែរបំណុលដែលកម្ពុជាជំពាក់ទៅជាជំនួយសំរាប់ការអភិវឌ្ឍន៍ដែលជាការរួមចំណែកដ៏សំខាន់ដល់ការអភិវឌ្ឍន៍ប្រទេសកម្ពុជា។ ឯកឧត្តម Ivo Barek អនុប្រធានព្រឹទ្ធសភានៃសាធារណរដ្ឋឆែក បានសំដែងនូវសេចក្តីរីករាយដែលបានអញ្ជើញមកបំពេញ

ទស្សនកិច្ចនៅកម្ពុជា និងបានគូសបញ្ជាក់ពីទំនាក់ទំនងមិត្តភាព និង សហប្រតិបត្តិការដ៏កក់ក្តៅរវាងកម្ពុជា-ឆែក ជាពិសេសទំនាក់ទំនងជាមួយ **ព្រះករុណា ព្រះបរមរតនកោដ្ឋ** និង **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** ។ ឯកឧត្តម Ivo Barek បានជំរាបជូនឯកឧត្តម អ៊ុច បូរិទ្ធ ជ្រាបថា នៅឆ្នាំក្រោយនេះ រដ្ឋាភិបាលឆែកនឹងពិនិត្យកែសំរួលឡើងវិញនូវយុទ្ធសាស្ត្រសហប្រតិបត្តិការជំនួយអភិវឌ្ឍន៍បរទេស (Development Cooperation Strategy)។ ក្នុងន័យនេះ ការផ្តល់ជំនួយអភិឌ្ឍន៍នឹងផ្តោតទៅតែប្រទេស៦ ប៉ុណ្ណោះនៅលើសកលលោក ក្នុងនោះប្រទេសកម្ពុជានៅតែជាប្រទេសដែលមានអាទិភាពក្នុងការជួយអភិវឌ្ឍន៍ ដោយយោងទៅលើទំនាក់ទំនងដ៏ល្អរវាងប្រទេសទាំងពីរ។ ឯកឧត្តមសង្ឃឹមថា អនុស្សារណៈយោគយល់គ្នាស្តីពីជំនួយអភិវឌ្ឍន៍ និងអនុស្សារណៈយោគយល់គ្នាស្តីពីការពិគ្រោះនយោបាយនៃក្រសួងការបរទេសនៃប្រទេសទាំងពីរនិងត្រូវបានចុះហត្ថលេខាឆាប់ៗខាងមុខនេះ ដើម្បីពង្រីកសហប្រតិបត្តិការឲ្យបានទូលំទូលាយថែមទៀត។ លើវិស័យអប់រំឯកឧត្តមបានគូសបញ្ជាក់ថា បច្ចុប្បន្ននេះមាននិស្សិតកម្ពុជា ប្រមាណ២០នាក់កំពុងបំពេញការសិក្សានៅសាធារណរដ្ឋឆែក ហើយឯកឧត្តមនឹងពិនិត្យមើលការបង្កើនអាហារូបកណ៍ដល់និស្សិតកម្ពុជាទៅសិក្សាអោយបានច្រើននៅតាមសកលវិទ្យាល័យដែលមានទីតាំងនៅតាមខេត្តនានានៃប្រទេសឆែកផងដែរ។ ទន្ទឹមនោះ ឯកឧត្តមក៏បានជំរាបជូនឯកឧត្តម អ៊ុច បូរិទ្ធ ថា ភាគីឆែកកំពុងពិនិត្យផ្តល់ការបណ្តុះបណ្តាលអ្នកការទូតវ័យក្មេង និងផ្តល់គ្រូបង្វឹកផ្នែកកីឡាបាល់ទាត់ម្នាក់ពីប្រទេសឆែកដល់ភាគីកម្ពុជា។ ក្រៅពីកិច្ចសហប្រតិបត្តិការលើវិស័យសុខាភិបាល អប់រំ បរិស្ថាន និងទឹកស្អាត ឯកឧត្តមចង់ឃើញកិច្ចសហប្រតិបត្តិការជិតស្និទរវាងអង្គការនីតិបញ្ញត្តិនៃប្រទេសទាំងពីរ និងសហប្រតិបត្តិការលើវិស័យដោះមីនអាកាសចរណ៍ ថាមពល និងការផ្លាស់ប្តូរទស្សនកិច្ចនៃគណៈប្រតិភូសភាពាណិជ្ជកម្មនៃប្រទេសទាំងពីរថែមទៀតដើម្បីជំរុញការងារវិនិយោគទុន។ ឯកឧត្តមក៏បានសម្តែងការពេញចិត្តក្នុងការចុះទៅបំពេញទស្សនកិច្ចនៅមន្ទីពេទ្យបង្អែកនៅខេត្តតាកែវ ដែលស្ថិតនៅក្នុងគំរោងជំនួយរបស់ប្រទេសឆែក។

ជាថ្មីម្តងទៀត ឯកឧត្តម អ៊ុច បូរិទ្ធ បានថ្លែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការប្តេជ្ញារបស់ភាគីឆែកក្នុងការធ្វើកិច្ចសហប្រតិបត្តិការជាមួយកម្ពុជានិងសង្ឃឹមយ៉ាងមាំថា កិច្ចសហប្រតិបត្តិការនេះនឹងរីកលូតលាស់ប្រកបដោយផ្លែផ្កា ដើម្បីផលប្រយោជន៍ទៅវិញទៅមកនៃប្រទេសទាំងពីរ។ ឆ្លៀតឱកាសនោះ ឯកឧត្តម អ៊ុច បូរិទ្ធ ក៏បានជំរាបជូនភ្ញៀវអំពីសភាពការណ៍នយោបាយនៅក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ននិងពីវិធានការណ៍ដែលរាជរដ្ឋាភិបាលបានប្រកាន់យកគឺស្ថិតនៅក្នុងក្របខ័ណ្ឌច្បាប់និងរដ្ឋធម្មនុញ្ញរបស់កម្ពុជាសំដៅពង្រឹងនិតិរដ្ឋ ការពារសន្តិភាព ស្ថេរភាពនិងសន្តិសុខជាតិ។ជាមួយគ្នានេះ ឯកឧត្តម

អ៊ុច បូររិទ្ធ បានគូសបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជានៅក្នុងការបន្តអនុវត្តនូវលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស ការគោរពសិទ្ធិមនុស្ស និងសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ សមស្របតាមផលប្រយោជន៍របស់ប្រទេសជាតិកម្ពុជា។

ជាកិច្ចឆ្លើយតប ឯកឧត្តម Ivo Barek បានគូសបញ្ជាក់ថា សាធារណរដ្ឋឆេកបានប្រកាន់យ៉ាងខ្ជាប់ខ្ជួននូវគោលនយោបាយរបស់ខ្លួនក្នុងការមិនជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងប្រទេសដទៃ។ជាធម្មតានៅពេលមានការសំរេចដោយ ក្រុមប្រឹក្សាធម្មនុញ្ញ និងតុលាការកំពូលនៃប្រទេសមួយ គឺពុំមានស្ថាប័នណាមួយមានសិទ្ធមិនទទួលស្គាល់ការសំរេចនោះបានទេ ។ នៅប្រទេសឆេកក៏ដូច្នោះដែរ។ ប្រទេសនានាត្រូវតែគោរពដល់ការសំរេចចិត្តរបស់កម្ពុជា។ ប្រទេសកម្ពុជាបានឆ្លងកាត់សង្គ្រាមស៊ីវិលជាច្រើនទស្សវត្សន៍មក ហើយ អាស្រ័យហេតុនេះ ការសំរេចណាមួយនោះរបស់កម្ពុជា គឺជាផ្លូវដែលនាំមកនូវសន្តិភាពដល់ប្រជាជនកម្ពុជា។ ឯកឧត្តម រីករាយគាំទ្រប្រទេសកម្ពុជាដើរនៅលើផ្លូវសន្តិភាព និងការអភិវឌ្ឍន៏។

កិច្ចប្រជុំបានបញ្ចប់ដោយបរិយាកាសមិត្តភាព រីករាយ និងស្និទស្នាល។

ភ្នំពេញថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៧